**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ២៩ សសរ**

# សេចក្តីសម្រេច

# ស្តីពី

# ការកំណត់ការធ្វើអាជីវកម្មខ្សាច់

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ដើម្បីការពារបាននូវលំនឹងបរិស្ថានធម្មជាតិ ទាំងដែនទឹកសាប ទាំងដែនសមុទ្រ ការធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទក្នុងក្របខ័ណ្ឌទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម :

១- ចំពោះការធ្វើអាជីវកម្មខ្សាច់ទឹកសាប :

ខ្សាច់ទឹកសាបដែលមាននៅក្នុងទន្លេ ស្ទឹង ព្រែក អូរ... អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបានក្នុងករណី:

-តែការធ្វើអាជីវកម្មនេះ គឺដើម្បីបម្រើដល់តម្រូវការប្រើប្រាស់ក្នុងស្រុកតែប៉ុណ្ណោះ

-អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបានតែនៅកន្លែងណា ដែលបច្ចេកទេសពិនិត្យទៅឃើញថា មានខ្សាច់ដុះកកស្ទះជាហេតុបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវទឹកតែប៉ុណ្ណោះ

-បញ្ឈប់ការនាំខ្សាច់ចេញទៅក្រៅប្រទេស។

២- ចំពោះការធ្វើអាជីវកម្មខ្សាច់សមុទ្រ :

-មិនអនុញ្ញាតអោយធ្វើអាជីវកម្មលើធនធានខ្សាច់សមុទ្រ ទោះជាទីតាំងនោះស្ថិតនៅឆ្ងាយពីឆ្នេរ ឬពីកោះក៏ដោយ។

-អាចអនុញ្ញាតបានចំពោះតែកន្លែងណាដែលមានខ្សាច់ដុះគោករាក់ និងអាចបំពេញវិញបានជាលក្ខណៈធម្មជាតិ តែត្រូវបំពេញល័ក្ខខ័ណ្ឌបច្ចេកទេសជាមុន។

**មាត្រា ២** : គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញជាបន្ទាន់ ទៅតាមការកំណត់នៃការធ្វើអាជីវកម្មដូចមានចែងក្នុងប្រការ ១ ដើម្បីធ្វើរបាយការណ៍ជូន សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីពិនិត្យ និង សំរេច។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤

“ដើម្បីជូនជ្រាប “

- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ : លោក ឈឹម ទីណា